ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ : ១៤៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សមាជិកជ្រើសតាំងសភាពាណិជ្ជកម្ម មណ្ឌលខេត្តស្វាយរៀង អាណត្តិទី១ លើកទី១

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសភាពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៦/០២២ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម មាត្រា២ និងមាត្រា១៥ ស្តីពីច្បាប់សភាពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៩១ អនក្រ.បក ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០២ ស្តីពីរបៀបរបប និងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា១០ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០២ ស្តីពីរបៀបរបប និងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម
- បានឃើញកំណត់ហេតុស្តីពីលទ្ធផលនៃការបោះឆ្នោតជ្រើសរើសសមាជិកជ្រើសតាំងសភាពាណិជ្ជកម្ម មណ្ឌលខេត្តស្វាយរៀង កាលពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ២០១៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សម្រេច**

**មាត្រា១.** ទទួលស្គាល់សមាជិកជ្រើសតាំងសភាពាណិជ្ជកម្មមណ្ឌលខេត្តស្វាយរៀង ចំនួន ១៥ រូប សម្រាប់អាណត្តិទី១ លើកទី១ ដូចខាងក្រោម:

១-លោក **សំ ស៊ីថាយ** | ២-លោកស្រី **លន់ ដាវី**
៣-លោក **ប៉ា ដារ៉ាល់** | ៤-លោក **នាង ចន្ថា**
៥-លោក **អ៊ុំ សៅ** | ៦-លោក **គង់ សាវ៉ាន់**
៧-លោកស្រី **ចាន់ សុគន្ធី** | ៨-លោក **កែវ សារឿន**
៩-លោកស្រី **សុខ សុគា** | ១០-កញ្ញា **សំ ចន្ធូ**
១១-លោក **ឃួន សុខេង** | ១២-លោកស្រី **សាំង រ័ត្នធីតា**
១៣-លោក **ជូ សារៈពង្ស** | ១៤-លោកស្រី **នង ម៉ូរ៉ា**
១៥-លោកស្រី **ទុំ ណាវី**

**មាត្រា២.** ទទួលស្គាល់លោក **សំ ស៊ីថាយ** ជាប្រធានសភាពាណិជ្ជកម្មមណ្ឌលខេត្តស្វាយរៀង សម្រាប់អាណត្តិទី១ លើកទី១។

**មាត្រា៣.** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អភិបាលនៃគណៈអភិបាលខេត្តស្វាយរៀង ប្រធានសភាពាណិជ្ជកម្មកម្ពុជា និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ និង មាត្រា២ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០១៦

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី**
សូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**កន្លែងទទួល៖**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-សាលារាជធានី-ខេត្ត
-សភាពាណិជ្ជកម្មកម្ពុជា
-ដូចមាត្រា៤
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ